# មហាព្រះវេស្សន្តរជាតក (សង្ខេប)

## *កណ្ឌកុមារបាព៌ (ទី៨)*

*__ជូជកោ__ រីជូជកចាស់ជរាដើរតាមមាគ៌ាអស់វេលាមួយថ្ងៃគត់បានដល់ទីជិតអាស្រមបទ ជូនជាវេលាសាយណ្ហសម័យថ្ងៃទន់ទាប ហៀបអស្តង្គត់រលត់ព្រះសូរ្យសែង ដោយអំណាចខំដើរតាមផ្លូវដាច់សង្វែង ក៏មានក្តីលំបាកយ៉ាងខ្លាំង ជូជកចុកចង្កេះរឹងគាំង ទើបយកដៃគក់បណ្តើរ គិតបណ្តើរថា "ថ្ងៃនេះនាងមទ្រីមកពីព្រៃវិញហើយ មុខជាមិនព្រមឲ្យកូនអញទេ អញដេកនៅទីនេះសិនចុះ ព្រឹកឡើងនាងមទ្រីទៅព្រៃបាត់ សឹមអញសុំកូននឹងព្រះវេស្សន្តរ" គិតដូច្នោះហើយ ក៏ដើរសសៀរមៀរតាមជំនៀរភ្នំ ឃើញថ្មុកជង្ហុក រអាងថ្មគាត់ក៏យកខ្លួនទៅលយល់ថាត្រូវល្អ ទើបប្រាសខ្លួនដេកលក់ជាសុខនៅទីនោះ។*

*ថ្ងៃងពីសម្តេចព្រះភគវតីស្រីមទ្រី ក្នុងវេលារាត្រីនោះទ្រង់ ឃើញសុបិននិមិត្តថាៈ បុរសម្នាក់ទាប សម្បុរខ្មៅ ស្លៀកសំពត់ អម្ចត់ត្រឹមជង្គង់ សៀតផ្កាចាររព្ធដ៏ត្រចៀក កាន់អាវុធមុតថ្វារត់ចូលមកក្នុងបរមសាលា ចាប់ព្រះនាងផ្តួលចុះ ឆ្កៀលយកព្រះនេត្រទាំងពីរ កាត់យកព្រះអង្សាទាំងសងខាង ពុះទ្រូងរូងយកថ្លើមបេះដូងទៅ។ ព្រះនាងតើនឡើងភិតភ័យតក្កមា ទើបព្រះនាងយាងយាត្រាចូលទៅរកព្រះស្វាមី គោះទ្វារអាស្រមបរមកុដិទាំងរាត្រីនោះឯង។*

*ព្រះវេស្សន្តរសួរថាៈ កោ ឯសោ នរណាអ្ហឹះនរណាហ្នឹង?*

*ព្រះនាងមទ្រីទូលថាៈ ខ្ញុំម្ចាស់ព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោស។*

*ព្រះវេស្សន្តរថាៈ នែ៎! ម្តេចក៏នាងមកក្នុងពេលពុំជូនកាលដូច្នេះ ក្រែងយើងបានប្តេជ្ញាគ្នាហើយឬ? ថាកុំឲ្យទៅមករកគ្នាក្នុងពេលយប់ស្ងាត់។*

*ព្រះនាងមទ្រីថាៈ ពិតដូច្នោះមែនហើយព្រះអង្គ ប៉ុន្តែសូមទ្រង់ព្រះសណ្តាប់ខ្ញុំម្ចាស់នឹងសារស័ព្ទឲ្យសព្វសេចក្តីព្រោះ អម្បាញមិញនេះខ្ញុំម្ចាស់យល់សុបិន្តឃើញអាក្រក់ណាស់ព្រះអង្គ។ ព្រះនាងថ្លែងសេចក្តីនៃសុបិន្តនិមិត្តថ្វាយសព្វគ្រប់។*

*ព្រះវេស្សន្តរថាៈ អើ! នាងនៅខាងក្រៅទ្វារនេះចុះ សុបិន្តនិមិត្តនៃនាងនោះមិនអាក្រក់ទេ! កុំភ័យអី! ទៅវិញចុះនាង ក្រែងកូនភ្ញាក់ឡើងវាខ្លាច។*

*អត្ថបទដោយ៖ មាស សុភាព*

ព្រឹកឡើងព្រះនាងមទ្រីនាំព្រះរាជបុត្រទាំងពីរទៅផ្ញើនឹងព្រះស្វាមីផ្ដែផ្ដាំសព្វសេចក្ដី ហើយក្សត្រីទ្រង់យកសង្រែកជង់រែក ជ្រនីទម្លក់ចូលទៅក្នុងព្រៃដើម្បីមូលផលាផល ព្រះជលនេត្រហូរហាមតាមព្រះនេត្រាព្រះឱរ៉ាតឹងព្អឹះទង្គឹះក្នុងព្រះហឫទ័យ ព្រះនាងនឹកមមៃមករកព្រះរាជបុត្រ និងព្រះរាជស្វាមីដោយក្ដីពិភាល់យ៉ាងខ្លាំងចំពោះសុបិន្តមិត្តនោះ។

រីឯជូជកភ្ញាក់ឡើងគិតថា: "ថ្ងៃនេះប្រហែលជានាងមទ្រីទៅព្រៃហើយ" គិតហើយក៏ដើរសំដៅឆ្ពោះទៅអាស្រមបទ។

ព្រះវេស្សន្តរទ្រង់ជ្រាបតាំងពីល្ងាចថា: "ព្រឹកនេះនឹងមានស្មូមមកសូមព្រះរាជបុត្រ" ទើបព្រឹកឡើងទ្រង់ចេញមកគង់ខាងក្រៅអាស្រមបទ ទន្ទឹងផ្លូវស្មូម ដូចជាមនុស្សប្រមឹកទន្ទឹងផ្លូវប្រពន្ធទៅផ្សារដើម្បីទិញស្រាមកផឹក លុះទ្រង់ទតឃើញជូជកដើរលោក់រលើ ទ្រង់ហៅជាលីកុមារថា: កូនអើយកូន! អ្នកក្រោកឈរឡើង! មើលនុ៎ះន៍! នរណាមកពីចំងាយ?

ជាលីក្រាបបង្គំទូលថា: បពិត្រព្រះបិតា ទូលព្រះបង្គំមើលទៅឃើញប្រាកដដូចជាព្រាហ្មណ៍ ព្រាហ្មណ៍នោះមកជាភ្ញៀវយើងហើយព្រះអង្គ។ ព្រះរាជកុមារទូលហើយ ក៏ស្ទុះតម្រង់ទៅទទួលព្រាហ្មណ៍ត្រូវជូជកគម្រាម។

ជូជកទន្ទមលបចូលទៅសួរសុខទុក្ខនឹងព្រះវេស្សន្តរ។

ព្រះវេស្សន្តរថា: យើងសុខសប្បាយទេព្រាហ្មណ៍ ទាំងមូលផលាហារក៏គ្រប់គ្រាន់ ពួកសត្វល្អិតសត្វទ្រូបាត ចតុប្បាទ ឥតយាយីយើងទេ តែតាំងពីយើងមកនៅព្រៃ៧ខែហើយ ឥតមានមនុស្សណាមួយមកជាភ្ញៀវយើងឡើយ។ ទើបតែនឹងបានឃើញ ព្រាហ្មណ៍ឯងជាតម្បូង អ្នកចូលលាងជើង អ្នកចូរបរិភោគផ្លែឈើ បើអ្នកចង់ផឹក ចូរអ្នកដងយកអំពីរោងខាងណោះ អ្នកស្វះពន្វះមកដល់ទីនេះ តើដើម្បីអ្វី?

ជូជកទូលថា: ខ្ញុំព្រះអង្គព្មថា: ព្រះរាជហឫទ័យរបស់ ព្រះអង្គពេញប្រៀបដោយចាគចេតនា ដូចជាទន្លេពេញប្រៀប ដោយទឹកមិនចេះអស់សព្វកាល កាលពេលមុនខ្ញុំព្រះអង្គមកទទួលព្រះរាជទានពុំទាន់នឹងគេ ទើបតែឥឡូវនេះបានតាមមកថ្វាយបង្គំដើម្បីសុំព្រះរាជបុត្រាបុត្រី។

អត្ថបទដោយ៖ មាស សុភាព

ព្រះវេស្សន្តរថា: យើងឲ្យ! យើងឥតរុញរាទេ! ប៉ុន្តែនៃបុត្រទាំងពីរនោះ ចេញទៅរកផលានុផលតាំងពីព្រឹកម៉្លេះ ដូច្នេះព្រាហ្មណ៍នៅទីនេះមួយយប់សិន លុះព្រឹកឡើងសឹមនាំយកកុមារទាំងពីរដែលមាតាស្និតស្នាងហើយនោះទៅចុះ។

ជូជកថា: ទូលព្រះបង្គំមិនគាប់ចិត្តនឹងការនៅទេ ក្រែងមានអន្តរាយ ទូលព្រះបង្គំនឹងទៅឥឡូវនេះខានពុំបាន។

ព្រះវេស្សន្តរថា: បើមិនចង់ជួបនឹងភរិយាយើងទេ អ្នកចូរនាំកុមារទាំងពីរនេះ ទៅថ្វាយចំពោះព្រះអយ្យកោចុះ មុខជាទ្រង់រីករាយនឹងព្រះរាជទានទ្រព្យដល់អ្នក។

ជូជកប្រកែកថា: ទេ!ទេ! ពុំហ៊ាននាំទៅទេព្រះអង្គ! ខ្លាចក្រែងព្រះអយ្យកោដណ្តើមយកព្រះរាជកុមារហើយ ឲ្យពួកអាមាត្យធ្វើរាជទណ្ឌចំពោះខ្ញុំព្រះអង្គ។

ព្រះវេស្សន្តរថា: ហៃកូនទាំងពីរជាទីស្រលាញ់របស់បិតា កូនចូរមកអាយចូរបំពេញបារមីរបស់បិតា ចូរស្រោចស្រពហឫទ័យរបស់បិតា ចូរកូនតាំងខ្លួនជាយាននាវា ឲ្យបិតានាំសត្វជិះឆ្លងចាក ជាតិជរាព្យាធិមរណៈ ទៅកាន់ត្រើយនាយ គឺនិព្វានណ៎ាកូន។

គ្រាដែលព្រះពោធិសត្វប្រទានព្រះរាជបុត្រដល់ព្រាហ្មណ៍នេះ ផែនដីក៏កម្រើក រំពើកញាប់ញ័រជាលើកទី៥។

កុមារទាំងពីរឮសម្តីព្រាហ្មណ៍ដ៏រឹងរូសដូច្នោះ ភ័យណាស់នាំគ្នារត់ទៅពួនឯស្រះ យកស្លឹកឈូកបាំងព្រះភ័ក្ត្រ។

ជូជកបោចវល្លិចងព្រះហត្ថានៃព្រះកុមារទាំងពីរព្រះអង្គ វាយនាំបណ្តើរទៅអំពីទីចំពោះព្រះភ័ក្ត្រនៃព្រះវេស្សន្តរ គ្រាន់ទៅផុតអំពីព្រះនេត្រា ជូជកជំពប់ដួលខ្ពោក។ កុមារទាំងពីរកំពង់មានទឹកព្រះនេត្រហូរសម្រាក់ ក៏របូតអំពីចំណងរត់ត្រសងមករកព្រះបិតា មានព្រះកាយាញ័រចំប្រប់ ដូចស្លឹកពោធិត្រូវខ្យល់ ឱបផើបទតព្រះភ័ក្ត្រព្រះបិតា។ ជាលីទូលអង្វរថា: ព្រះមាតាចេញទៅព្រៃហើយ ម្តេចក៏ព្រះបិតាពុំបង្អង់យើងខ្ញុំជួបនឹងព្រះមាតាសិនសឹមទ្រង់ព្រះរាជទាន តែខ្ញុំជាលីទៅចុះ កុំព្រះរាជទានក្រឹស្នាឡើយ ព្រោះនាងនៅតូចណាស់។ ឯជូជកតាមមកចាប់កញ្ឆក់ចងទាញយកទៅទៀត វាយវាត់ឥតប្រណី។ ព្រះមហាឥសី ទ្រង់គិតថានឹងចាប់ផ្ទួសព្រះខ័នថ្វាប្រហារ យកព្រះរាជបុត្រទាំងពីរមកវិញ តែទ្រង់ទប់បាន ដោយមាន

អត្ថបទដោយ៖ មាស សុភាព

ព្រះតម្រិះថា ប្រពៃណីនៃពោធិសត្វអំពីបុរាណ មិនដែលខានធ្វើនូវបញ្ច:មហាបរិច្ចាគ គឺ: ធនបរិច្ចាគ១ អង្គបរិច្ចាគ១ ជីវិតបរិច្ចាគ១ បុត្តបរិច្ចាគ១ និងភរិយាបរិច្ចាគ១។

កុមារទាំងពីរដែលជូជកនាំទៅ ត្រូវទុក្ខវេទនាគ្របសង្កត់អត់ទ្រាំពុំបាន ទ្រង់ព្រះសំណោកសោកាថា: ឱ! ជើងយើងខ្ញុំពុរពងអស់ហើយ ព្រះមាតាអើយ! ផ្លូវសោតក៏ឆ្ងាយដាច់ស្រយាល ព្រះសុរិយាក៏កាន់តែទន់ទាប ព្រាហ្មណ៍ក៏នាំយើងទៅបង្ខំណាស់ យើងខ្ញុំសុំថ្វាយបង្គំពួកទេវតារក្សាព្រៃ សូមទេវតាទាំងឡាយទូលព្រះមាតាផង សូមឲ្យមាតាយាងមកតាមផ្លូវនេះឆាប់ៗរ៉ា នឹងបានជួបនឹងយើងខ្ញុំភ្លាម ឱ! ព្រះមាតាអើយសូមទ្រង់យាងមកឆាប់ៗ!

*(ចប់ កណ្ឌទី៨ កណ្ឌកុមារបាព៌ សូមរង់ចាំតាមដានកណ្ឌទី៩ នៅសប្តាហ៍ក្រោយ)*

អត្ថបទដោយ៖ មាស សុភាព